**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ទៅជាសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង ទៅជាសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

មាត្រា ១.-

ទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ទៅជា **សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ** " University of Puthisastra " សរសេរកាត់ជាភាសាខ្មែរ "ព.ស" និងសរសេរកាត់ជាភាសាអង់គ្លេស " U.P. " ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអាគារលេខ ៥៥ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេស ដល់គ្រូបង្រៀន និងសាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ តាមឯកទេសរបស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- កសាងផែនការអភិវឌ្ឍ សម្រាប់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- គ្រប់គ្រងនិស្សិត បុគ្គលិក សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិ របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណង ធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

មាត្រា ៣.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សា ត្រូវបានរៀបចំ ឱ្យមានមហាវិទ្យាល័យចំនួន ០៥ (ប្រាំ) :

១. មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

២. មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

៣. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

៥- មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យពុទ្ធិសាស្ត្រ អាចប្តូរឈ្មោះ ប្តូរទីតាំង ពង្រីកទីតាំង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទអប់រំដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍសាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៥.-

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៦.-

សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវគ្រប់គ្រង ដោយសាកលវិទ្យាធិការប្រតិបត្តិ ០១ (មួយ)រូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧.-

សាកលវិទ្យាធិការប្រតិបត្តិ នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល
- ធ្វើរបាយការណ៍គ្រប់គ្រង ប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់ របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងគោរពតាមវិធានការ ស្តីពីការគ្រប់គ្រងបុគ្គលិក
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយភ្ញៀវជន ។

មាត្រា ៨.-

និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ តាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែល សាកលវិទ្យាល័យនេះបំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ